ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..០៥៧..សឯល

## សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
## ស្តីពី
## វិធានការការពារការចម្លងវីរុសកូវីដ១៩ នៅតាមកន្លែងកាត់សក់ ថែរក្សាសម្ផស្ស និងសេវាពាក់ព័ន្ធ

ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត និងការចូលរួមការពារការចម្លងវីរុសកូវីដ១៩ របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន បន្ថែមលើវិធានការនានាដែលយើងទាំងអស់គ្នាបាននិងកំពុងតែអនុវត្ត ក្រសួងសុខាភិបាលសូមធ្វើការណែនាំដល់សាធារណជនទាំងអស់ឲ្យបានជ្រាបពីវិធានការការពារការចម្លងវីរុសកូវីដ១៩ នៅតាមកន្លែងកាត់សក់ ថែរក្សាសម្ផស្ស និងសេវាពាក់ព័ន្ធផ្សេងៗ ដែលមានចំណុចសំខាន់ៗដូចខាងក្រោមនេះ៖

**១- នៅតាមកន្លែងកាត់សក់ ថែរក្សាសម្ផស្ស កាត់ក្រចក និងសេវាពាក់ព័ន្ធផ្សេងៗទៀត នៅទូទាំងប្រទេស៖**

ក. សូមកាត់បន្ថយជាអតិប្បរមានូវចំនួនជងដែលត្រូវរកសេវាទាំងនោះ (បើអាចធ្វើបាន) នៅក្នុងដំណាក់កាលទប់ស្កាត់ការចម្លងវីរុសកូវីដ១៩នេះ

ខ. ប្រសិនបើចាំបាច់ខានមិនបាន សូមអនុវត្តនូវការការពារខ្លួនដូចតទៅ៖

- បុគ្គលម្នាក់ៗ ត្រូវពាក់ម៉ាស់ (ទាំងជាងកាត់សក់ និងអ្នកកាត់សក់) ឲ្យត្រូវតាមក្បួនខ្នាត ជាចាំបាច់ រហូតដល់ការកាត់សក់បានចប់សព្វគ្រប់
- ជាងកាត់សក់ត្រូវលាងដៃជាមួយនឹងសាប៊ូ ឬអាល់កុល ឬទឹកដែលសម្រាប់លាងដៃឲ្យបានស្អាត មុននឹងចាប់កាត់សក់ជូនភ្ញៀវ
- ត្រូវរក្សាអនាម័យស្អាតល្អកន្លែងកាត់សក់ ឬកន្លែងរក្សាថែសម្ផស្ស ដោយជូតសម្អាតរៀងរាល់ពេលដែលមានភ្ញៀវមកកាត់សក់ ឬមករកសេវាថែរក្សាសម្ផស្ស នៅកន្លែងរបស់ខ្លួន
- ពេលកាត់សក់ ឬពេលធ្វើសក់ ឬកិច្ចការថែរក្សាសម្ផស្សផ្សេងៗ ត្រូវជៀសវាងការនិយាយស្ទើទល់មុខគ្នា (បើជៀសមិនបាន និយាយឲ្យបានតិចជាទីបំផុត ហើយគេចមុខចេញពីគ្នាកុំឲ្យតទល់មុខគ្នា)។ បុគ្គលនីមួយៗអាចអនុវត្តការកោរមុខរបស់ខ្លួន ដោយខ្លួនឯងបាន
- សម្ភារៈប្រើប្រាស់សម្រាប់កាត់សក់ ឬថែរក្សាសម្ផស្ស ចាំបាច់ត្រូវតែលាងសម្អាត (បើលាងនឹងសាប៊ូមិនបាន សូមលាង ឬត្រាំនឹងអាល់កុលចំនួន៤០ ទៅ៦០វិនាទី ជាចាំបាច់) រៀងរាល់ក្រោយពេលប្រើប្រាស់សម្ភារៈទាំងអស់នោះរួច និងមុនពេលយកមកប្រើប្រាស់លើបុគ្គលម្នាក់ទៀត ជាចាំបាច់
- ក្រណាត់ ឬកន្សែង ដែលប្រើប្រាស់សម្រាប់គ្របមុខ ឬគ្របដងខ្លួនបុគ្គលដែលត្រូវកាត់សក់ ចាំបាច់ ហាមដាច់ខាតមិនត្រូវប្រើបន្តពីបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត គឺត្រូវប្រើ ខ

តែម្តងគត់សម្រាប់បុគ្គលម្នាក់ ហើយត្រូវតែបោកគក់សម្អាតនឹងសាប៊ូ ហាលថ្ងៃជាប្រចាំ នូវក្រណាត់ ឬកន្សែង ដែលបានប្រើប្រាស់សម្រាប់បុគ្គលម្នាក់រួចហើយនោះ:

- ជាងកាត់សក់ ឬថែរក្សាសម្ផស្ស ត្រូវពាក់ស្រោមដៃជ័រប្លាស្ទិក ឬហ្គង់ (Glove)
- កៅអីកាត់សក់ ឬកៅអីអង្គុយ ត្រូវដាក់ឲ្យមានគម្លាតពីគ្នាលើសពី ១ម៉ែត្រ កន្លះ ឡើង
- ក្រោយពីកាត់សក់រួច ត្រូវមុជទឹក ដុសសាប៊ូ កក់សក់ សម្អាតខ្លួនប្រាណភ្លាមៗ មុននឹងជួបជាមួយសមាជិកក្រុមគ្រួសាររបស់ខ្លួននៅក្នុងផ្ទះ
- ទាំងអ្នកកាត់សក់ និងអ្នកដែលត្រូវកាត់សក់ ត្រូវចៀសវាងការចាប់ដៃគ្នា និងចៀសវាងការប៉ះពាល់គ្នាផ្ទាល់ជាអតិប្បរិមា ក្នុងអំឡុងពេលកាត់សក់ ឬសកម្មភាពថែសម្ផស្ស។
- បុគ្គលដែលមានបញ្ហាសុខភាព ឬមិនស្រួលខ្លួន ត្រូវស្វែងរកការពិនិត្យព្យាបាល ដោយហៅទៅលេខ ១១៥ ឬទៅមន្ទីរពេទ្យរដ្ឋ ដោយមិនត្រូវមករកសេវាកាត់សក់ ថែរក្សាសម្ផស្ស និងសេវាពាក់ព័ន្ធឡើយ។

**២.សម្រាប់កន្លែងផ្តល់សេវាផ្សេងៗ:**

វិធានការការពារការចម្លងវីរុសកូវីដ១៩ សំខាន់ៗមានដូចជា:

- ត្រូវជូតសម្អាតកន្លែងលក់ដូររបស់ខ្លួនឲ្យបានស្អាតល្អ ជាមួយនឹងទឹកសាប៊ូ ឬអាល់កុល ឲ្យបានញឹកញាប់
- អនុវត្តការរក្សាចម្ងាយពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ឲ្យបានលើសពី ១ម៉ែត្រកន្លះឡើងទៅ
- កុំប្រជ្រៀតគ្នា និងចៀសវាងនៅកន្លែងដែលមានមនុស្សច្រើន
- ប្រើប្រាស់ម៉ាស់ ឬក្រមា ឬកន្សែង ខ្ទប់មាត់ពេលក្អកកណ្តាស់ ជាចាំបាច់
- ចៀសវាងការប៉ះពាល់គ្នាដោយផ្ទាល់ បើចៀសមិនបានត្រូវប្រើស្រោមដៃជ័រប្លាស្ទិក ឬហ្គង់ (Glove) ជាចាំបាច់
- រក្សាអនាម័យ និងសម្អាតសម្ភារៈ និងរបស់របរដែលដាក់លក់ដូរ ឲ្យបានជាប់ជាប្រចាំ
- ឧស្សាហ៍លាងដៃជាមួយនឹងសាប៊ូ ឬអាល់កុល ឬជែលលាងដៃ ក្រោយពីចាប់កាន់វត្ថុអ្វីមួយ
- មិនត្រូវយកដៃមកប៉ះពាល់ផ្ទៃមុខរបស់ខ្លួន ប្រសិនបើមិនទាន់បានលាងសម្អាតទេនោះ
- បុគ្គលដែលមានបញ្ហាសុខភាព ឬមិនស្រួលខ្លួន ត្រូវស្វែងរកការពិនិត្យ ព្យាបាល ដោយហៅទៅលេខ ១១៥ ឬទៅមន្ទីរពេទ្យរដ្ឋ ដោយមិនត្រូវមករកសេវាកាត់សក់ ថែរក្សាសម្ផស្ស និងសេវាពាក់ព័ន្ធឡើយ។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ ហើយក្រសួងក៏សូមអំពាវនាវដល់សាធារណជនទាំងអស់ សូមចូលរួមអនុវត្តតាមការណែនាំខាងលើនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីចូលរួមចំណែកកាត់ផ្តាច់ការចម្លងវីរុសកូវីដ១៩ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ និងទៅសហគមន៍របស់យើង។ សូមបងប្អូនសាធារណជនទាំងអស់ ទទួលបាននូវសុខភាពល្អ ចៀសផុតពីការចម្លងវីរុសកូវីដ១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃអាទិត្យ ១៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**